**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់ សាកលវិទ្យាល័យ លីមកុកវីង យូនីវើស៊ីធី អហ្វ ក្រេអេតធីវ តិចណូឡូជី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក. ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក. ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញប្រកាសលេខ ១៤៣៥ អយក.ប្រក ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០៧ ស្តីពីលក្ខខណ្ឌ និងលក្ខណវិនិច្ឆ័យលម្អិត សម្រាប់ការបង្កើតគ្រឹះស្ថានឧត្តមសិក្សា
- បានឃើញយោបល់របស់ក្រសួងអប់រំ យុវជន និងកីឡា តាមលិខិតលេខ ៤៧២ អយក.ឧស. ចុះថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០០៨

## ស ម្រេ ច

**មាត្រា ១** : ទទួលស្គាល់ការបង្កើតគ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា **សាកលវិទ្យាល័យ លីមកុកវីង យូនីវើស៊ីធី អហ្វ គ្រេអេតទីវ តិចណូឡូជី** ( Limkokwing University of Creative Technology ) សរសេរកាត់ជាភាសាខ្មែរ " ស.ល.យ.គ.ត. " និងសរសេរកាត់ជាភាសាអង់គ្លេស "L.U.C.T "។

**មាត្រា ២** : សាកលវិទ្យាល័យ លីមកុកវីង យូនីវើស៊ីធី អហ្វ គ្រេអេតទីវ តិចណូឡូជី មានទីតាំងស្ថិតនៅអគារលេខ ៩ ផ្លូវលេខ ១៩៨៤-១៩៨៦ ភូមិភ្នំពេញថ្មី សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ និងស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៣** : សាកលវិទ្យាល័យ លីមកុកវីង យូនីវើស៊ីធី អហ្វ គ្រេអេតទីវ តិចណូឡូជី ធ្វើការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររង បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ ។ សាកលវិទ្យាល័យនេះ ត្រូវរៀបចំកម្មវិធីសិក្សាលម្អិតតាមកម្រិត និងមុខជំនាញ ដើម្បីសុំការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា បន្ទាប់ពីចាប់ដំណើរការបាន ៦ ( ប្រាំមួយ ) ខែ ។

**មាត្រា ៤** : សាកលវិទ្យាល័យ លីមកុកវីង យូនីវើស៊ីធី អហ្វ គ្រេអេតទីវ តិចណូឡូជី មាន ប្រាំមហាវិទ្យាល័យ :

១-មហាវិទ្យាល័យ សិល្បៈ អក្សរសាស្ត្រ និងមនុស្សសាស្ត្រ

២-មហាវិទ្យាល័យ គណិតសាស្ត្រ វិទ្យាសាស្ត្រ និងវិស្វកម្ម

៣-មហាវិទ្យាល័យ វិទ្យាសាស្ត្រសង្គម និងទំនាក់ទំនងអន្តរជាតិ

៤-មហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជកម្ម

៥-មហាវិទ្យាល័យ ស្ថាបត្យកម្ម និងការរចនា

ទៅថ្ងៃអនាគត សាកលវិទ្យាល័យនេះ អាចបើកសាខា មហាវិទ្យាល័យ មុខជំនាញ កម្រិត ឬថ្នាក់ប្រភេទបណ្តុះបណ្តាល ប្តូរ ឬពង្រីកទីតាំងថ្មី ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៥** : សាកលវិទ្យាល័យ លីមកុកវីង យូនីវើស៊ីធី អហ្វ គ្រេអេតទីវ តិចណូឡូជី មានក្រុមប្រឹក្សាភិបាលមួយដើម្បីពិនិត្យ និងសម្រេចលើគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ការអភិវឌ្ឍកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត ។ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែង នៃសាកលវិទ្យាល័យ លីមកុកវីង យូនីវើស៊ីធី អហ្វ គ្រេអេតទីវ តិចណូឡូជី ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យ ។

**មាត្រា ៦ ៖** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យ លីមកុកវីង យូនីវើស៊ីធី អហ្វ ក្រេអេតធីវ តិចណូឡូជី មានភារកិច្ច ៖

-ទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យនេះ និងធានាឱ្យមានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម

-គោរព និងអនុវត្តតាមការណែនាំ និងបទដ្ឋានដែលពាក់ព័ន្ធនឹងការងារបណ្តុះបណ្តាលរបស់ក្រសួងអប់រំ យុវជន និងកីឡា និងច្បាប់របស់រាជរដ្ឋាភិបាល សំដៅធានាគុណភាពអប់រំ

-រៀបចំរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល ស្របតាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា

-ធ្វើរបាយការណ៍ អំពីការងារបណ្តុះបណ្តាល មកនាយកដ្ឋានឧត្តមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់។

**មាត្រា ៧ ៖** និស្សិតដែលបានរៀនចប់កម្មវិធីសិក្សា នៅសាកលវិទ្យាល័យ លីមកុកវីង យូនីវើស៊ីធី អហ្វ ក្រេអេតធីវ តិចណូឡូជី និងទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងមុខជំនាញ ដែលបានសិក្សា។ សញ្ញាបត្រនេះ ផ្តល់ឱ្យដោយសាកលវិទ្យាល័យ លីមកុកវីង យូនីវើស៊ីធី អហ្វ ក្រេអេតធីវ តិចណូឡូជី ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីសាកលវិទ្យាល័យ លីមកុកវីង យូនីវើស៊ីធី អហ្វ ក្រេអេតធីវ តិចណូឡូជី បំពេញ និងអនុវត្តបានតាមគោលការណ៍ និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៨ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ស្ថាប័នពាក់ព័ន្ធ និងសាកលវិទ្យាល័យ លីមកុកវីង យូនីវើស៊ីធី អហ្វ ក្រេអេតធីវ តិចណូឡូជី ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- សាលាក្រុងភ្នំពេញ
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ